01085515

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
08 / 04 / 2015
ម៉ោង (Time/Heure) : 13:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/17/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកឯកសារ និង ស្តាប់សក្ខីកម្មសាក្សីបន្ថែមម្នាក់ ដែលពាក់ព័ន្ធនឹងស្រុកត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ ដែលជាផ្នែកមួយនៃសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C * C.E.T.C. អង្គជំនុំជម្រះសាលាដំបូង

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ សុំឱ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរចំនួន ២២ ពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ ដែលបានផ្តល់ចម្លើយក្នុងសំណុំរឿង ០០៤ និងសុំស្តាប់សក្ខីកម្មសាក្សីម្នាក់បន្ថែមទៀត ដែលពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ (ឯកសារ E319/17 កថាខណ្ឌ ១ ដល់ ១១) ។ ចម្លើយដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ១១ និងទី ១៨ ខែ កុម្ភៈ

ឆ្នាំ ២០១៥ (ឯកសារ E319/12 និង E319/13) ត្រូវបានកំណត់អត្តសញ្ញាណបន្ថែមទៀតនៅក្នុងតារាងឧបសម្ព័ន្ធនៃសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលរួមមានការពិពណ៌នាទូទៅអំពីចម្លើយ រួមទាំងចំណុចនានានៅក្នុងដីកាដំណោះស្រាយ ដែលត្រូវបានអះអាងថាពាក់ព័ន្ធនឹងចម្លើយទាំងនេះ (*សូមមើល* ឧបសម្ព័ន្ធសម្ងាត់ ឆ ឯកសារ E319/17.1.1)។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ចម្លើយទាំងនេះ "មានការពាក់ព័ន្ធយ៉ាងខ្លាំង" ទៅនឹងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E319/17 កថាខណ្ឌ ៣)។ ពុំមានភាគីណាមួយឆ្លើយតបទៅនឹងសំណើសុំឱ្យទទួលយកចម្លើយទាំង ២២ នេះទេ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សាក្សីបន្ថែមដែលបានស្នើឡើង[1] អាចផ្តល់ "ភស្តុតាងយ៉ាងសំខាន់តែមួយគត់" ដោយសារតែតួនាទីរបស់គាត់នៅក្នុងស្រុកត្រាំកក់ក្នុងអំឡុងពេលដែលពាក់ព័ន្ធ និងព័ត៌មានដែលគាត់អាចផ្តល់ពាក់ព័ន្ធនឹងចំណុចនេះ (ឯកសារ E319/17 កថាខណ្ឌ ៥ ដល់ ៩)។ មេធាវីការពារក្តី នួន ជា និង ខៀវ សំផន គាំទ្រដល់ការស្តាប់សក្ខីកម្មសាក្សីបន្ថែម 2-TCW-979 (ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥ ទំព័រ ៣៦, ៦៤, ៦៩) ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនជំទាស់ទេ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មី បើខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣)។ វិធាន ៨៧(៤) ក៏តម្រូវផងដែរថា ភាគីនានាដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវដាក់សារណាមួយដែលមានសំអាងហេតុ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ ឬ មិនអាចស្វែងរកបាន បន្ទាប់ពីបានអនុវត្តនូវការបំពេញការងារដោយយកចិត្តទុកដាក់សមស្របរួចហើយ។ អង្គជំនុំជម្រះបានលើកឡើងពីមុនថា ឯកសារមួយដែលមិនត្រូវបានបញ្ចូលក្នុងបញ្ជីដើមរបស់ភាគីតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង គឺជាភស្តុតាងថ្មីដែលត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏ប៉ុន្តែ ឯកសារនេះអាចទទួល

---

[1] អង្គជំនុំជម្រះសាលាដំបូងកំណត់រហស្សនាម 2-TCW-979 ដល់សាក្សីនេះ។

យកបាន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើបែបនេះ (ឯកសារ E282/2 ដោយយោងទៅឯកសារ E190 កថាខណ្ឌ ១៩ ដល់ ២១)។

៣. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលស្នើសុំឱ្យទទួលយក ត្រូវបានធ្វើឡើងនៅឆ្នាំ ២០១៣ ឬ ២០១៤ ហេតុនេះ ឯកសារទាំងនេះមិនអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការនៅ ខែ មិថុនា ឆ្នាំ ២០១១ ទេ។ គាត់លើកឡើងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឱ្យគាត់បង្ហាញចម្លើយទាំងនេះនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ២១ ខែ មករា និង ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ឯកសារ E319/17 កថាខណ្ឌ ៤)។

៤. អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា ចម្លើយទាំងអស់ត្រូវបានផ្តល់នៅឆ្នាំ ២០១៣ និង ២០១៤ រួមទាំងចម្លើយរបស់សាក្សីដែលបានស្នើឡើង គឺសាក្សី 2-TCW-979 ផងដែរ ហេតុនេះ ចម្លើយទាំងនេះមិនអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការក្នុងឆ្នាំ ២០១១ ទេ (*សូមមើល* ឯកសារ E319/11/1 កថាខណ្ឌ ៤)។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឱ្យបង្ហាញចម្លើយទាំងនេះទើបតែនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ (ឯកសារ E319/12.1.1 ឯកសារ E319/12.2) និង ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ (ឯកសារ E319/13.1.1 ឯកសារ E319/13.1.2 ឯកសារ E319/13.1.3) ប៉ុណ្ណោះ។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បង្ហាញចម្លើយទាំងនេះនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ១១ និងទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ (សូមមើល ឯកសារ E319/12 ឯកសារ E319/13 និងឧបសម្ព័ន្ធសម្ងាត់ ឆ)។ ហេតុនេះ ការសុំដាក់ឯកសារទាំងនេះមិនអាចធ្វើបាននៅមុនពេលចាប់ផ្តើមសំណុំរឿង ០០២/០២ ទេ ហើយសំណើនេះធ្វើឡើងទាន់ពេលវេលា។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា កំណត់ហេតុស្តាប់ចម្លើយត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហេតុ-នេះ ចម្លើយទាំងនេះបានបំពេញបទដ្ឋាននៃភាពអាចជឿជាក់បាន និងយថាភាព *តាមការវិភាគបឋម* (ឯកសារ E319/11/1 កថាខណ្ឌ ៥)។ បន្ទាប់ពីបានពិនិត្យទៅលើចម្លើយដែលបានស្នើឡើង អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា ចម្លើយទាំងនេះមានភស្តុតាងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ និងគោលនយោបាយនានា

ដែលត្រូវបានចោទប្រកាន់ថា បានអនុវត្តនៅក្នុងសហឧក្រិដ្ឋកម្មរួម។ ចម្លើយទាំងនេះមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត និងមានភាពពាក់ព័ន្ធ*តាមការវិភាគបឋម* ទៅនឹងសំណុំរឿង ០០២/០២។

៥. ការបញ្ចូលសាក្សីថ្មីចាំបាច់ត្រូវតែបំពេញលក្ខខណ្ឌតម្រូវនានាដែលមានចែងក្នុងវិធាន ៨៧(៤) (ឯកសារ E307/1 កថាខណ្ឌ ៥)។ អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកថា កិច្ចដំណើរការនីតិវិធីនសវនាការត្រូវមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី និងភាពចាំបាច់ក្នុងការបញ្ចប់សវនាការក្នុងរយៈពេលមួយដែលសមស្រប (ឯកសារ E312 កថាខណ្ឌ ២២)។

៦. សហព្រះរាជអាជ្ញាអន្តរជាតិបានដឹងព័ត៌មានអំពីសាក្សី 2-TCW-979 នេះនៅខែ ឧសភា ឆ្នាំ ២០១៤ ដោយមានសិទ្ធិចូលពិនិត្យមើលកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ (សូមមើល ឧបសម្ព័ន្ធសម្ងាត់ ធ និង ឯកសារ E319/12.3.2)។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិមិនអាចរកបានសក្ខីកម្មរបស់គាត់នៅមុនពេលចាប់ផ្តើមសវនាការក្នុងឆ្នាំ ២០១១ ទេ។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាអន្តរជាតិមានកាតព្វកិច្ចស្នើសុំការស្តាប់សក្ខីកម្មសាក្សីរូបនេះឱ្យបានទាន់ពេលវេលានា។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានស្នើសុំឱ្យកោះហៅសាក្សី 2-TCW-979 មុនពេលចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ ឬ ក្នុងពេលណាមួយទេរហូតមកទល់នឹងពេលនេះ។ គោលជំហរបែបនេះគឺផ្ទុយទៅនឹងវិធីសាស្ត្រទូទៅដែលសហព្រះរាជអាជ្ញាដែលបានប្រកាន់យកពាក់ព័ន្ធនឹងបុគ្គលផ្សេងៗទៀតដែលត្រូវបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ ឬ ០០៤ ទោះបីជាកំណត់ហេតុស្តាប់ចម្លើយក្នុងសំណុំរឿងទាំងនោះមិនទាន់ត្រូវបានអនុញ្ញាតឱ្យបង្ហាញនៅឡើយក៏ដោយ (ឯកសារ E307/3/2 កថាខណ្ឌ ១៩ ដល់ ២២។ *សូមមើល ផងដែរ* ឯកសារ E305/6 កថាខណ្ឌ ២៣ ដល់ ២៤)។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានអនុវត្តការបំពេញការងារដោយយកចិត្តទុកដាក់ ហើយថា សំណើសុំស្តាប់សក្ខីកម្មសាក្សីរូបនេះមិនបានដាក់ទាន់ពេលវេលាទេ។

01085519



៧. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជាប្រយោជន៍នៃយុត្តិធម៌ ត្រូវស្តាប់សក្ខីកម្មសាក្សី 2-TCW-979។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា សាក្សីរូបនេះធ្លាប់កាន់តួនាទីសំខាន់ពីឆ្នាំ ១៩៧៣ ដល់ ឆ្នាំ ១៩៧៩ នៅក្នុងស្រុកត្រាំកក់ (ឯកសារ E319/17 កថាខណ្ឌ ៥។ ឯកសារ E319/12.3.2 ត្រង់ A22 ដល់ A25, A28)។ ពាក់ព័ន្ធនឹងតួនាទីរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សាក្សី 2-TCW-979 អាចផ្តល់ព័ត៌មានមានសំខាន់ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់គាត់ត្រូវបានមេធាវីការពារក្តី នួន ជា យកមកប្រើប្រាស់យ៉ាងច្រើនក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី 2-TCW-803 (*សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥ ទំព័រ ៩-១០, ២៤-២៦, ៣០-៣៩)។ សាក្សី 2-TCW-979 ក៏អាចជួយអង្គជំនុំជម្រះក្នុងការបង្ហាញពីយថាភាពនៃឯកសារ ទាក់ទិននឹងស្រុកត្រាំកក់ និង មន្ទីរសន្តិសុខក្រាំងតាចាន់ (ឯកសារ E319/17 កថាខណ្ឌ ៧។ *សូមមើល* ផងដែរ ប្រតិចារឹកចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥ ទំព័រ ២៣-២៦)។ លើសពីនេះទៀត ភាគីផ្សេងៗទៀតមិនជំទាស់ទៅនឹងការស្តាប់សក្ខីកម្មរបស់គាត់ទេ ដោយអាចកំណត់ពេលវេលាផ្តល់សក្ខីកម្មរបស់គាត់នៅពេលណាមួយក្រោយពេលអង្គជំនុំជម្រះធ្វើសវនាការវិញ បន្ទាប់ពីបានផ្អាកមួយរយៈ និង នៅចន្លោះពេលនៃបញ្ចប់ការបង្ហាញ ភស្តុតាងដែលទាក់ទិននឹងស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ហេតុនេះការស្តាប់សក្ខីកម្មសាក្សី 2-TCW-979 មានហេតុផលសមស្រប។

៨. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា លក្ខខណ្ឌតម្រូវនានានៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ ហើយឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលស្នើសុំឱ្យទទួលយកចម្លើយនានាដែលបានលើកឡើងខាងលើ ជាភស្តុតាងក្នុងសំណុំរឿង ០០២/០២ និងសំណើសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-979។ អង្គជំនុំជម្រះក៏រម្លឹកភាគីថា ការប្រើប្រាស់ចម្លើយទាំងនេះត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី ដែលមានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឯកសារ E319/7។

៩. អនុស្សរណៈនេះជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះ ទៅនឹងឯកសារ E319/17។